**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/៩៥៦ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរំសាយឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និង ក្រុមប្រឹក្សាកំណែទម្រង់ចំណុះឱ្យឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើត **គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ** ហៅកាត់ "គ.ក.រ" ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងវិស័យកែទម្រង់រដ្ឋបាលសាធារណៈ។



www.pheakdeylaw.com

## ជំពូកទី២
## បេសកកម្ម និង សមាសភាព

**មាត្រា២ .-**

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានបេសកកម្មផ្តួចផ្តើម រៀបចំ ដាក់ឱ្យដំណើរការ និង តាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ស្របតាមគោលនយោបាយនិងការតម្រង់ទិសរបស់រាជរដ្ឋាភិបាល។

**មាត្រា៣ .-**

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានភារកិច្ចដូចខាងក្រោម៖

- ផ្តួចផ្តើមនិងលើកសំណើជូនរាជរដ្ឋាភិបាលនូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់ធ្វើឱ្យសម្រេចជោគជ័យគោលដៅនៃកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ មានជាអាទិ៍ គោល-នយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ការកែទម្រង់ប្រព័ន្ធបៀវត្ស ការរៀបចំនិងការ ដាក់ឱ្យអនុវត្តស្តង់ដារសេវាសាធារណៈ ការត្រួតពិនិត្យរចនាសម្ព័ន្ធ និងប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្សក្នុងក្រសួង ស្ថាប័ន
- លើកសំណើជូនរាជរដ្ឋាភិបាលនូវគ្រប់គម្រោងច្បាប់ លិខិតបទដ្ឋាន និងគ្រប់វិធានការចាំបាច់ក្នុងការ ដាក់ឱ្យដំណើរការកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ
- លើកសំណើជូនរាជរដ្ឋាភិបាលក្នុងការចេញសេចក្តីសម្រេច និង សេចក្តីណែនាំចាំបាច់ដល់ក្រសួង ស្ថាប័នក្នុងការដាក់ឱ្យដំណើរការកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងព្រំដែនសមត្ថកិច្ចរបស់ខ្លួន
- លើកសំណើជូនរាជរដ្ឋាភិបាលក្នុងការដាក់ចេញនូវវិធានការ ដើម្បីរួមចំណែកក្នុងការលើកស្ទួយគុណភាព ប្រសិទ្ធភាព និងគណនេយ្យភាពនៃសេវាសាធារណៈ និងការប្រើប្រាស់ធនធានមនុស្ស
- អនុវត្តសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលក្នុងការដាក់ឱ្យដំណើរការគោលនយោបាយ យុទ្ធសាស្ត្រនិង ផែនការសកម្មភាពនៃកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួលបណ្តាសកម្មភាពរបស់ក្រសួង ស្ថាប័ននានា ដែលទាក់ទងនឹងកម្មវិធីកែទម្រង់រដ្ឋបាល សាធារណៈ
- ផ្តល់ជូនដល់ក្រសួង ស្ថាប័ន ក្នុងព្រំដែនសមត្ថកិច្ចរបស់ខ្លួននូវជំនួយបច្ចេកទេសលើការងារកែទម្រង់ រដ្ឋបាលសាធារណៈ
- តាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ នៅតាមក្រសួង ស្ថាប័ននៅថ្នាក់ ជាតិនិងថ្នាក់ក្រោមជាតិ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃវឌ្ឍនភាពជូនរាជរដ្ឋាភិបាល
- សហការនិងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ក្នុងការស្វែងរកជំនួយបច្ចេកទេសនិងហិរញ្ញប្បទាន ដើម្បីគាំទ្រដល់កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ



www.pheakdeylaw.com

- ដឹកនាំ គ្រប់គ្រង និងជំរុញការងារផ្សព្វផ្សាយព័ត៌មានស្តីពីគោលដៅ សកម្មភាព និងសមិទ្ធផលនៃការងារកែទម្រង់រដ្ឋបាលសាធារណៈ
- សហការនិងសម្របសម្រួលជាមួយកម្មវិធីកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

**មាត្រា៤.-**

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | ជាប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | មួយរូប អនុប្រធានប្រចាំការ |
| ៣. រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | មួយរូប សមាជិក |
| ៤. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | មួយរូប សមាជិក |
| ៥. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | មួយរូប សមាជិក |
| ៦. រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | មួយរូប សមាជិក |
| ៧. រដ្ឋលេខាធិការក្រសួងសុខាភិបាល | មួយរូប សមាជិក |
| ៨. រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | មួយរូប សមាជិក |
| ៩. រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | មួយរូប សមាជិក |
| ១០. រដ្ឋលេខាធិការក្រសួងកិច្ចការនារី | មួយរូប សមាជិក |
| ១១. រដ្ឋលេខាធិការក្រសួងផែនការ | មួយរូប សមាជិក |
| ១២. រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៣. អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ | លេខាធិការនិង |

ទទួលដឹកនាំលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។

ក្រៅពីសមាជិកខាងលើ គ.ក.រ អាចស្នើបន្ថែមសមាជិកជារដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ឬតំណាងនៃក្រសួងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល តាមការចាំបាច់។

ការតែងតាំងសមាសភាពនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣

## រចនាសម្ព័ន្ធការងារ និង របៀបរបបដំណើរការការងារ

**មាត្រា៥.-**

ដើម្បីបំពេញបេសកកម្មនិងសម្រេចភារកិច្ចដូចមានចែងក្នុងមាត្រា២ និង មាត្រា៣ ខាងលើ គ.ក.រ អាចបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់តាមវិស័យ ឬអនុគណៈកម្មាធិការ ឬក្រុមការងារបច្ចេកទេសផ្សេងទៀតទៅតាមការចាំបាច់ សម្រាប់ជួយដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្តនិងតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលតាមវិស័យ ឬអនុវិស័យនីមួយៗ ព្រមទាំងសម្រាប់ជួយសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍និងគ្រប់ភាគីដែលមានការពាក់ព័ន្ធ។



www.pheakdeylaw.com

**មាត្រា៦.-**

គណៈកម្មាធិការដឹកនាំការងារតាមវិស័យ អនុគណៈកម្មាធិការ និងក្រុមការងារដែលមានលក្ខណៈអន្តរក្រសួង ត្រូវបង្កើតឡើងដោយអនុក្រឹត្យ តាមសំណើរបស់ **គ.ក.ទ**។

**មាត្រា៧ .-**

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈធ្វើការតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធានប្រចាំការតាមការប្រគល់សិទ្ធិរបស់ប្រធាន។ ក្នុងករណីមិនអាចចូលរួមប្រជុំបាន អនុប្រធាន និង សមាជិកគណៈកម្មាធិការត្រូវចាត់តាំងតំណាងចូលរួម ដែលមានសិទ្ធិសម្រេចជំនួសខ្លួន។

ក្នុងករណីប្រធានអវត្តមាន ឬ មានការអាក់ខាន ដោយប្រការណាមួយ អនុប្រធានប្រចាំការបំពេញមុខងារជាប្រធានស្ដីទីដឹកនាំជំនួសដោយស្វ័យប្រវត្តិ។

**មាត្រា៨ .-**

ប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬ តំណាងរបស់ប្រធានស្ថាប័ន ឬ អាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត មកចូលរួមប្រជុំនិងបំពេញការងារស្របតាមខ្លឹមសារដែលមានចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា៩ .-**

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ព្រមទាំងគណៈកម្មាធិការដឹកនាំការងារតាមវិស័យ អនុគណៈកម្មាធិការ និងក្រុមការងារបច្ចេកទេស មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍និងតំណាងសង្គមស៊ីវិល ព្រមទាំងទីប្រឹក្សា អ្នកជំនាញការជាតិនិងអន្តរជាតិ ឱ្យចូលរួមប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍ឬផ្ដល់យោបល់ទៅតាមភាពចាំបាច់នៃការងារ។

**មាត្រា១០ .-**

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានលេខាធិការដ្ឋានជាសេនាធិការ សម្រាប់ការអនុវត្តមុខងារ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ប្រើប្រាស់ត្រារបស់ក្រសួងមុខងារសាធារណៈសម្រាប់ដំណើរការការងារ។

## ជំពូកទី ៤

## ធនធាននិងថវិការបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

**មាត្រា១១ .-**

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានប្រភពធនធានផ្ដត់ផ្គង់ដោយថវិកាជាតិ ដែលដាក់បញ្ចូលថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងមុខងារសាធារណៈ។

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានសិទ្ធិទទួលនិងគ្រប់គ្រងធនធានដែលបានមកពីប្រភពហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ។



www.pheakdeylaw.com

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com